# កិច្ចព្រមព្រៀង

# រវាង

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

# ស្ដីពី

# កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ

# ឆ្នាំ ២០១៧ - ២០១៨

PBC

# រាជរដ្ឋាភិបាលកម្ពុជា

## និង

# រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីនៃទំនាក់ទំនងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងបំណងពង្រឹង និងរឹតចំណងទំនាក់ទំនងមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ក្នុងស្មារតីនៃភាពជាដៃគូ

ដោយយល់ថា ការថែរក្សាទំនាក់ទំនងនេះគឺជាមូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀងនេះ

ក្នុងគោលបំណងរួមចំណែកការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

យោងរបាយការណ៍សង្ខេប ស្តីពីកិច្ចចរចាអន្តររដ្ឋាភិបាល នាថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៧ នៅរាជធានីភ្នំពេញ

បានព្រមព្រៀងដូចខាងក្រោម ៖

## មាត្រា ១

១- រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជាតាមរយៈធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) នូវហិរញ្ញប្បទានសរុបចំនួន ១៦.០០០.០០០ អឺរ៉ូ (ដប់ប្រាំមួយលានអឺរ៉ូ)

១- សម្រាប់គម្រោងដូចខាងក្រោម ៖

ក- កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ- ដំណាក់កាលទី ៧ ដែលមានហិរញ្ញប្បទាន រហូតដល់ ៧.០០០.០០០ អឺរ៉ូ (ប្រាំពីរលានអឺរ៉ូ)

ខ- ការផ្តល់ហិរញ្ញប្បទានរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សម្រាប់កម្មវិធីកែលម្អគុណភាព និងសមធម៌សុខភាព ដែលមានហិរញ្ញប្បទានរហូតដល់ ៨.០០០.០០០ អឺរ៉ូ (ប្រាំបីលានអឺរ៉ូ)

គ- ការផ្តល់ហិរញ្ញប្បទានរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សម្រាប់វិធានការគាំទ្រក្នុងកម្មវិធីកែលម្អគុណភាព និងសមធម៌សុខភាព ដែលមានហិរញ្ញប្បទានរហូតដល់ ១.០០០.០០០ អឺរ៉ូ (មួយលានអឺរ៉ូ)

ប្រសិនបើពិនិត្យឃើញថា គម្រោងទាំងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គាំទ្រ ។

២- កិច្ចព្រមព្រៀងនេះក៏មានវិសាលភាពគ្របដណ្តប់ផងដែរ ប្រសិនបើនៅថ្ងៃក្រោយ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់អាចផ្តល់ហិរញ្ញប្បទានបន្ថែមជូនរាជរដ្ឋាភិបាលកម្ពុជា តាមរយៈ KfW សម្រាប់រៀបចំគម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ឬសម្រាប់ផ្តល់ចំណាត់ការចាំបាច់នានា ដើម្បីអនុវត្ត និងគាំទ្រគម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ។

PBC

## មាត្រា ២

១- ការប្រើប្រាស់ហិរញ្ញប្បទានដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងលក្ខខណ្ឌ ព្រមទាំងនីតិវិធីនៃការផ្តល់កិច្ចសន្យា ត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងដែលនឹងត្រូវចុះហត្ថលេខារវាង KfW និងស្ថាប័នទទួលហិរញ្ញប្បទាន ហើយត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ និងបទប្បញ្ញត្តិនានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

២- ការសន្យាផ្តល់ហិរញ្ញប្បទានឥតសំណងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវផុតសុពលភាព ប្រសិនបើកិច្ចព្រមព្រៀងហិរញ្ញប្បទានពាក់ព័ន្ធ មិនត្រូវបានចុះហត្ថលេខាក្នុងរយៈពេល ៤ ឆ្នាំ បន្ទាប់ពីឆ្នាំនៃការសន្យាត្រូវបានប្រកាសឡើង ។ ការផ្តល់ហិរញ្ញប្បទាននេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១ ។ កាលបរិច្ឆេទផុតសុពលភាពសម្រាប់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងការបើកផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីកែលម្អគុណភាព និងសមធមិសុខភាព ដូចមានចែងក្នុងមាត្រា ១.១.ខ នៃកិច្ចព្រមព្រៀងនេះ គឺថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២១ ។

៣- រាជរដ្ឋាភិបាលកម្ពុជា ក្នុងករណីមិនមែនជាអ្នកទទួលហិរញ្ញប្បទាននេះដោយផ្ទាល់ ត្រូវធានាការសងប្រាក់ទាន់ពេលកំណត់ទៅឱ្យ KfW វិញ ដោយផ្អែកលើកិច្ចសន្យាហិរញ្ញប្បទានដែលនឹងត្រូវបានចុះហត្ថលេខា ស្របតាមកថាខណ្ឌ ១ ខាងលើ ។

## មាត្រា ៣

រាជរដ្ឋាភិបាលកម្ពុជា ត្រូវបង់ជំនួស KfW នូវពន្ធ និងអាករផ្ទាល់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងការសម្រេចកិច្ចសន្យា និងការអនុវត្តកិច្ចសន្យា ដូចមានចែងក្នុងមាត្រា ២.១ នៃកិច្ចព្រមព្រៀងនេះ ។ រាល់អាករលើតម្លៃបន្ថែម និងពន្ធមិនចំពោះផ្សេងៗ ក៏ដូចជាពន្ធលើការប្រើប្រាស់ជាក់លាក់ណាមួយ នឹងត្រូវបង់ជំនួសដោយរាជរដ្ឋាភិបាលកម្ពុជា ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវបង់ជំនួស KfW នូវថ្លៃសេវាសាធារណៈដទៃទៀត ។

## មាត្រា ៤

រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុញ្ញាតឱ្យអ្នកធ្វើដំណើរ និងអ្នកផ្គត់ផ្គង់ អាចជ្រើសរើសដោយសេរីនូវសហគ្រាសដឹកជញ្ជូន សម្រាប់ការដឹកជញ្ជូនមនុស្ស និងទំនិញតាមសមុទ្រ ផ្លូវគោក ឬអាកាស ក្នុងក្របខណ្ឌនៃការផ្តល់ហិរញ្ញប្បទាននេះ ហើយចៀសវាងការដាក់វិធានការណាមួយដែលអាចរារាំងការចូលរួម ឬបង្កការលំបាកដល់ការចូលរួមដោយស្មើភាពរបស់សហគ្រាសដឹកជញ្ជូន ដែលមានទីតាំងធុរកិច្ចនៅក្នុងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ព្រមទាំងផ្តល់អាជ្ញាប័ណ្ណចាំបាច់នានា សម្រាប់ការចូលរួមរបស់សហគ្រាសទាំងនោះ ។

PBC

## មាត្រា ៥

១- កិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមានគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

២- កិច្ចព្រមព្រៀងនេះ អាចនឹងត្រូវបញ្ចប់មុនកាលកំណត់បាន ។ ភាគីម្ខាងនៃកិច្ចព្រមព្រៀងអាចស្នើសុំបញ្ចប់ជាលាយលក្ខណ៍អក្សរតាមរយៈយន្តការការទូតក្នុងពេលណាមួយ ។ ការបញ្ចប់កិច្ចព្រមព្រៀង នឹងត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសំណើជាលាយលក្ខណ៍អក្សរនោះត្រូវបានទទួលដោយភាគីម្ខាងទៀតនៃកិច្ចព្រមព្រៀង ។

៣- ភាគីនៃកិច្ចព្រមព្រៀង អាចស្នើសុំធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះបាន ។

៤- រាល់វិវាទពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តកិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយដោយសន្តិវិធីរវាងភាគីទាំងពីរតាមរយៈការពិភាក្សា ឬការចរចា ។

៥- យោងតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងចុះបញ្ជីនៃកិច្ចព្រមព្រៀងនេះ នៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ បន្ទាប់ពីកិច្ចព្រមព្រៀងនេះបានចូលជាធរមាន ។ ភាគីហត្ថលេខីម្ខាងទៀត នឹងទទួលព័ត៌មានពីការចុះបញ្ជីនៅអង្គការសហប្រជាជាតិ និងលេខចុះបញ្ជីនេះ បន្ទាប់ពីមានការបញ្ជាក់ពីលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៧ ជាភាសាខ្មែរ, ភាសាអាល្លឺម៉ង់ និងភាសាអង់គ្លេស ។ អត្ថបទទាំង ៣ ភាសានេះ មានតម្លៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នារវាងអត្ថបទភាសាអាល្លឺម៉ង់ និងភាសាខ្មែរ នោះអត្ថបទជាភាសាអង់គ្លេស នឹងត្រូវទុកជាបានការ ។

**តំណាង**
**រាជរដ្ឋាភិបាលកម្ពុជា**

Sean B. Chin

**ជិន ប៊ុនស៊ាន**
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**តំណាង**
**រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**

Ingo Karsten

**Ingo Karsten**
**ឯកអគ្គរដ្ឋទូត**
**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា**

CBC

IK